ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៣៨ ប្រក.កសក.

# ប្រកាស
## ស្តីពីនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្វ
## និង ផលិតផលមានដើមកំណើតពីសត្វ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ - ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 - 726 129 Fax: (855) 23 217 320

- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និង រុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**ប្រការ ១ :** ប្រកាសនេះសំដៅកំណត់នូវនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វលើកលែងតែផល ផលិតផលជលផល ក្នុងការនាំចេញ នាំចូល នាំឆ្លងកាត់ ដឹកជញ្ជូនក្នុងផ្ទៃប្រទេស ក្នុងគោលបំណងទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វ ការពារសុខភាពសត្វ និង ការពារសុខភាពសាធារណៈ ។

**ប្រការ ២ :** រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលធ្វើការនាំចេញ នាំចូល នាំឆ្លងកាត់ ឬ ដឹកជញ្ជូនក្នុងផ្ទៃប្រទេស នូវសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ ត្រូវមានឯកសារដូចខាងក្រោម ÷

**ក-សម្រាប់ការនាំចេញទៅក្រៅប្រទេស ត្រូវមាន :**

- គោលការណ៍អនុញ្ញាតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចំពោះនីតិបុគ្គល
- លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ
- លិខិតអនុញ្ញាតឱ្យប្រមូលទិញសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ
- វិញ្ញាបនបត្រអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- អត្តសញ្ញាណប័ណ្ណសត្វ ឬ ភិនសត្វ ឬ អត្តសញ្ញាណប័ណ្ណ (ឯកសារ) សម្រាប់សម្គាល់ផលិតផលមានដើមកំណើតពីសត្វ។

**ខ-សម្រាប់ការនាំចូល នាំឆ្លងកាត់ប្រទេស ត្រូវមាន ÷**

- គោលការណ៍អនុញ្ញាតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- វិញ្ញាបនបត្របញ្ជាក់ប្រភពដើមនៃសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចំពោះនីតិបុគ្គល
- លិខិតអនុញ្ញាតនាំចេញ នាំឆ្លងកាត់ សត្វ ឬ ផលិតផលមានដើមកំណើតពីសត្វពីស្ថាប័នមានសមត្ថកិច្ច នៃប្រទេសនាំចេញ
- អត្តសញ្ញាណប័ណ្ណសត្វ ឬ ភិនសត្វ ឬ អត្តសញ្ញាណប័ណ្ណ ( ឯកសារ ) សម្រាប់សម្គាល់ផលិតផលមានដើមកំណើតពីសត្វ
- វិញ្ញាបនបត្រអនាម័យសត្វ ឬ វិញ្ញាបនបត្រអនាម័យផលិតផលមានដើមកំណើតពីសត្វ នៃប្រទេសនាំចេញ
- កិច្ចសន្យាស្តីពីការនាំចូល ឬ នាំឆ្លងកាត់ សត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ រវាងរូបវន្តបុគ្គល ឬ នីតិបុគ្គលនោះ ជាមួយនាយកដ្ឋានផលិតកម្ម និង បសុពេទ្យាបាល ។

**គ-សម្រាប់ការដឹកជញ្ជូនក្នុងផ្ទៃប្រទេស ត្រូវមាន ÷**

- លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ
- លិខិតអនុញ្ញាតឱ្យប្រមូលទិញសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ
- អត្តសញ្ញាណប័ណ្ណសត្វ ឬ ភិនសត្វ ឬ អត្តសញ្ញាណប័ណ្ណ (ឯកសារ) សម្រាប់សម្គាល់ផលិតផលមានដើមកំណើតពីសត្វ
- វិញ្ញាបនបត្រអនាម័យសត្វ ឬ វិញ្ញាបនបត្រអនាម័យផលិតផលមានដើមកំណើតពីសត្វ ។

**ប្រការ ៣ :** រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលធ្វើការនាំចេញ នាំចូល នាំឆ្លងកាត់ សត្វ ឬ ផលិតផលមានដើមកំណើតពីសត្វត្រូវដាក់ពាក្យសុំត្រួតពិនិត្យអនាម័យសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ នៅនាយកដ្ឋានផលិតកម្ម និង បសុពេទ្យាបាល ។

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលដឹកជញ្ជូនសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ ក្នុងផ្ទៃប្រទេសត្រូវដាក់ពាក្យសុំត្រួតពិនិត្យអនាម័យសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ នៅការិយាល័យផលិតកម្ម និង បសុពេទ្យាបាលរាជធានី ខេត្ត សាមី ។

ពាក្យសុំត្រួតពិនិត្យអនាម័យសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ១-៣ នៃប្រកាសនេះ ។

**ប្រការ ៤ :** ក្នុងន័យធានាដល់សុខភាពសត្វ និង សុខភាពសាធារណៈ រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលធ្វើអាជីវកម្មប្រមូលទិញសត្វ ឬផលិតផលមានដើមកំណើតពីសត្វលើកលែងសត្វព្រៃ សំណាក និង ផលិតផលសត្វព្រៃពីរាជធានី ខេត្តណាមួយ ទៅខេត្ត ដទៃ ឬ សម្រាប់នាំចេញទៅក្រៅប្រទេស ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម និង លិខិតអនុញ្ញាតប្រមូលទិញនៅនាយកដ្ឋានផលិតកម្ម និង បសុពេទ្យាបាល ។

ការអនុញ្ញាតឱ្យប្រមូលទិញសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វរបស់និតិបុគ្គល ត្រូវបានការយល់ព្រមជាមុន ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលធ្វើអាជីវកម្មប្រមូលទិញសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ ក្នុងរង្វង់រាជធានី ខេត្ត ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម និង លិខិតអនុញ្ញាតប្រមូលទិញ នៅការិយាល័យផលិតកម្ម និង បសុព្យាបាលរាជធានី ខេត្ត សាមី ។

គំរូ សំណុំឯកសារ សម្រាប់ស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម និង លិខិតអនុញ្ញាតប្រមូលទិញ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ៤ - ១៤ នៃប្រកាស~~នេះ ។~~

**ប្រការ ៥ :** លិខិតអនុញ្ញាតធ្វើអាជីវកម្មប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ត្រូវបានកំណត់សុពលភាពក្នុងរយៈពេល១២ (ដប់ពីរ) ខែ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត ។

លិខិតអនុញ្ញាតប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ត្រូវបានកំណត់សុពលភាពក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត ។

**ប្រការ ៦ :** គំរូលិខិតអនុញ្ញាតប្រើប្រាស់ក្នុងការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ ដូចខាងក្រោម ÷

**ក- ចេញដោយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល**

- លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វ មានអក្សរសម្គាល់លេខលិខិត ផប.លអ
- លិខិតអនុញ្ញាតប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វ មានអក្សរសម្គាល់លេខលិខិត ផប.ប្រទ
- វិញ្ញាបនបត្រអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ មានអក្សរសម្គាល់លេខលិខិត ផប.វិអ
- លិខិតអនុញ្ញាតដឹកជញ្ជូនសត្វ និង ផលិតផលមានដើមកំណើតពីសត្វ មានអក្សរសម្គាល់លេខលិខិត ផប.លដជ ។

**ខ- ចេញដោយការិយាល័យផលិតកម្ម និង បសុព្យាបាលរាជធានី ខេត្ត**

- លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វ មានអក្សរសម្គាល់ លេខលិខិត កផប.លអ
- លិខិតអនុញ្ញាតប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វ មានអក្សរសម្គាល់លេខលិខិត កផប.ប្រទ

- វិញ្ញាបនបត្រអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ មានអក្សរសម្គាល់ [illegible]
- លិខិតអនុញ្ញាតដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វមានអក្សរសម្គាល់លេខ [illegible]។

**ប្រការ ៧ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨ :** អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ប្រធានមន្ទីរកសិកម្ម ប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលរាជធានី ខេត្ត ប្រធាន អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ច រៀងៗ ខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ១០ ឆ្នាំ ២០០៩

**រដ្ឋមន្ត្រី**

**ចាន់ សារុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរកសិកម្ម រាជធានី/ខេត្ត....................**

**ការិយាល័យ ផលិតកម្ម និង បសុព្យាបាល**

លេខ:......................កផប.ប្រទ

## លិខិតអនុញ្ញាតប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

- យោងអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត
- យោងលិខិតលេខ...............កសក. ចុះថ្ងៃទី............ខែ.........ឆ្នាំ២០០....របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- យោងលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មប្រមូលទិញសត្វ/ផលិតផលមានដើមកំណើតពីសត្វ លេខ..............ចុះថ្ងៃទី.......... ខែ .........ឆ្នាំ ............. របស់ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល
- យោងពាក្យស្នើសុំប្រមូលទិញសត្វ/ផលិតផលមានដើមកំណើតពីសត្វរបស់សាមីខ្លួនចុះថ្ងៃទី........ខែ....... ឆ្នាំ...........។

អនុញ្ញាតឱ្យឈ្មោះ...........................................ភេទ.............អាយុ...........ឆ្នាំ ជនជាតិ................សញ្ជាតិ....................... មុខរបរ.........................................ទីលំនៅផ្ទះលេខ.............. ផ្លូវ................ ភូមិ............................ ឃុំ/សង្កាត់ ............................ក្រុង/ស្រុក/ខណ្ឌ..........................រាជធានី/ខេត្ត..................................មានអត្តសញ្ញាណប័ណ្ណ លេខ...............ប្រមូលទិញសត្វ/ផលិតផលមានដើមកំណើតពីសត្វ...............ចំនួន.................ក្បាល/គ.ក្រ ពីរាជធានី/ខេត្ត...............................................ដើម្បី.....................................................នៅ.......................................។

លិខិតនេះមានសុពលភាពចាប់ពីថ្ងៃទី........ខែ.....................ឆ្នាំ.................ដល់ថ្ងៃទី.........ខែ...................ឆ្នាំ..............។

សាមីជនដែលបានទទួលការអនុញ្ញាត ត្រូវយកលិខិតនេះបង្ហាញផ្នែកផលិតកម្ម និង បសុព្យាបាល ក្រុង ស្រុក ខណ្ឌ ដើម្បីកំណត់កន្លែង ត្រូវប្រមូលទិញក្នុងការអនុវត្តអាជីវកម្ម ឱ្យបានល្អប្រសើរសមស្របតាមលក្ខណៈបច្ចេកទេស។

..........................ថ្ងៃទី...........ខែ............ឆ្នាំ២០០......

**ប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាល**

**<u>ចំលងជូន:</u>**

- នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល "ដើម្បីជូនជ្រាប"
- ការិយាល័យផលិតកម្ម "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

លេខ:......................ផប.ប្រទ

# លិខិតអនុញ្ញាតប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

- យោងអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- យោងលិខិតលេខ..............កសក. ចុះថ្ងៃទី...........ខែ.........ឆ្នាំ២០០....របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- យោងលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មប្រមូលទិញសត្វ/ផលិតផលមានដើមកំណើតពីសត្វ លេខ...................... ចុះថ្ងៃទី..............ខែ ............ឆ្នាំ ............. របស់ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល
- យោងពាក្យស្នើសុំប្រមូលទិញសត្វ និងផលិតផលមានដើមកំណើតពីសត្វរបស់សាមីខ្លួនចុះថ្ងៃទី........ខែ ...... ឆ្នាំ.........។

អនុញ្ញាតឱ្យឈ្មោះ..........................................ភេទ............អាយុ...........ឆ្នាំ ជនជាតិ...............សញ្ជាតិ...................... មុខរបរ.............................................ទីលំនៅផ្ទះលេខ.............. ផ្លូវ................ ភូមិ............................ ឃុំ/សង្កាត់ ..........................ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត....................................មានអត្តសញ្ញាណប័ណ្ណ លេខ...............ប្រមូលទិញសត្វ/ផលិតផលមានដើមកំណើតពីសត្វ....................ចំនួន............ក្បាល/គ.ក្រពីរាជធានី/ខេត្ត...........................................ដើម្បី.............................នៅ..............................................................។

លិខិតនេះមានសុពលភាពចាប់ពីថ្ងៃទី........ខែ.................ឆ្នាំ..............ដល់ថ្ងៃទី.........ខែ....................ឆ្នាំ..............។

សាមីជនដែលបានទទួលការអនុញ្ញាតត្រូវយកលិខិតនេះបង្ហាញការិយាល័យផលិតកម្មនិងបសុព្យាបាលខេត្ត ដើម្បីកំណត់កន្លែងត្រូវប្រមូលទិញ និងចេញវិញ្ញាបនបត្រសំរាប់ដឹកជញ្ជូន ដោយមានចុះទិដ្ឋាការមន្ទីរកសិកម្មខេត្ត...............................។

ធ្វើនៅភ្នំពេញ ថ្ងៃទី...........ខែ............ឆ្នាំ ...............

**ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល**

**ចំលងជូន:**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ "ដើម្បីជូនជ្រាប"
- មន្ទីរកសិកម្ម រាជធានី/ខេត្ត "ដើម្បីជ្រាប និង ជំរុញការអនុវត្ត"
- ការិយាល័យផលិតកម្ម និង បសុព្យាបាលរាជធានី/ ខេត្ត "ដើម្បីអនុវត្ត"
- ការិយាល័យផលិតកម្ម "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋាន ផលិតកម្ម និង បសុពេទ្យាបាល　　　　　　　　លេខប័ណ្ណ : ____________

លេខ :........................ផ.ប លផជ

## លិខិតអនុញ្ញាតដឹកជញ្ជូន
## សត្វ និង ផលិតផលមានដើមកំណើតពីសត្វ

- យោងអនុក្រឹត្យលេខ១៦ អនក្រ.បក ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣
- យោងសេចក្តីជូនដំណឹងលេខ :......................សជណ. ចុះថ្ងៃទី ........ខែ.............. ឆ្នាំ ២០០.. របស់.............. ..............................................
- យោងលិខិតលេខ :..........................................កសក. ចុះថ្ងៃទី ............ខែ...............ឆ្នាំ ២០០.. របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- យោងលិខិតស្នើសុំដឹកជញ្ជូនរបស់ ...........................................លេខ ..............................ចុះថ្ងៃទី...........ខែ..................ឆ្នាំ ២០០... ។

អនុញ្ញាតឱ្យឈ្មោះ ...............................................................ភេទ.......... មុខរបរបច្ចុប្បន្ន ...........................................................

កាន់អត្តសញ្ញាណប័ណ្ណលេខ.......................................................... ចេញដោយ...................................................................

ទីលំនៅបច្ចុប្បន្នផ្ទះលេខ........ភូមិ.....................ឃុំ/សង្កាត់.......................ក្រុង/ស្រុក/ខណ្ឌ..............................រាជធានី/ខេត្ត.............

ដឹកជញ្ជូនសត្វ / ផលិតផលមានដើមកំណើតពីសត្វ.................................................................................................................

ចំនួន / បរិមាណ :..............................................................................................................................................................

ចេញដំណើរពី : ភូមិ...............ឃុំ/សង្កាត់..........................ក្រុង/ស្រុក/ខណ្ឌ ...................................រាជធានី/ខេត្ត........................

នៅថ្ងៃទី ............ខែ ..................ឆ្នាំ ២០០...

ឆ្ពោះទៅប្រទេស.......................................................តាមផ្លូវ:...................................................................................................

ទៅកាន់ឈ្មោះក្រុមហ៊ុន/អ្នកទទួល..........................................................................................................................................

ក្រុង/ស្រុក/ខណ្ឌ ..................................................................................រាជធានី/ខេត្ត........................................................

មធ្យោបាយដឹកជញ្ជូន :..................................................................................ស្លាកលេខ :..............................................

ផុតសុពលភាពថ្ងៃទី ............................ ខែ ............................ ឆ្នាំ ២០០.....

វិញ្ញាបនបត្រអនាម័យសត្វ/ផលិតផលមានដើមកំណើតពីសត្វលេខ:...................................... ចុះថ្ងៃទី..............ខែ.................ឆ្នាំ២០០...

ចេញដោយ :..........................................................................................................................................................................

បង្កាន់ដៃបង់សោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វលេខ:..................... ចុះថ្ងៃទី.......ខែ..........ឆ្នាំ២០០...

ចំនួនទឹកប្រាក់......................................................................................................................................................................

ចេញដោយ :..........................................................................................................................................................................

យោបល់របស់បសុពេទ្យ :.......................................................................................................................................................

............................................................................................................................................................................................ ។

..............ថ្ងៃទី ......... ខែ ........... ឆ្នាំ ២០០..

ប្រធាននាយកដ្ឋាន ផលិតកម្ម និង បសុពេទ្យាបាល

បានឃើញ និង ឯកភាព

..........ថ្ងៃទី......... ខែ.................. ឆ្នាំ ២០០...

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរកសិកម្មរាជធានី/ខេត្ត...............**

**ការិយាល័យផលិតកម្ម និងបសុព្យាបាល**

លេខ :..............ក.ផ.ប.វិអ

## វិញ្ញាបនបត្រអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

- ប្រភេទសត្វ :..................................................................................................
- ចំនួនសត្វសរុប:..................................ក្បាល ឈ្មោល:..............ក្បាល ញី :...............ក្បាល
- អត្តសញ្ញាណ :..................................................................................................
- ប្រភេទផលិតផលមានដើមកំណើតពីសត្វ:....................................................................
- បរិមាណផលិតផលឬកញ្ចប់:..............................ទម្ងន់សរុប:............................................
- របៀបវេចខ្ចប់:..................................................................................................
- សត្វ/ផលិតផលមានដើមកំណើតពីសត្វ:នាំចេញពី:ភូមិ :........................ឃុំ/សង្កាត់ :.....................

  ក្រុង/ស្រុក/ខណ្ឌ :........................................រាជធានី/ខេត្ត.........................................
- ឆ្ពោះទៅកាន់:ភូមិ :........................................ឃុំ/សង្កាត់ :...........................................

  ក្រុង/ស្រុក/ខណ្ឌ :........................................រាជធានី/ខេត្ត.........................................
- អ្នកនាំចេញ :ឈ្មោះ :.......................................មុខរបរ:..............................................

  អាសយដ្ឋានបច្ចុប្បន្ន.............................................................................................
- អ្នកទទួល : ឈ្មោះ ..........................................មុខរបរ..............................................

  អាសយដ្ឋាន .........................................................................................................
- មធ្យោបាយដឹកជញ្ជូន :........................................ស្លាកលេខ....................តាមផ្លូវ...................
- យោបល់បសុពេទ្យ..................................................................................................

  ...........................................................................................................................។

ធ្វើនៅ......................ថ្ងៃទី.........ខែ.............ឆ្នាំ ២០០.....

**បានឃើញ និង ឯកភាព** **ប្រធានការិយាល័យ ផលិតកម្ម និង បសុព្យាបាល**

.........ថ្ងៃទី........ខែ............ឆ្នាំ ២០០....

**ប្រធានមន្ទីរកសិកម្ម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត
៤ x ៦

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល
លេខ :.........................ផប.លអ

## លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

- យោងអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- យោងប្រកាសលេខ.........................ប្រក.កសក ចុះថ្ងៃទី...............ខែ............ឆ្នាំ២០០......ស្តីពីនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- យោងលិខិត..........................កសក.ចុះថ្ងៃទី..................ខែ....................ឆ្នាំ ២០០..........របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

បានអនុញ្ញាតឱ្យលោក/លោកស្រី...........................................ភេទ.................អាយុ..........ឆ្នាំ ជនជាតិ....................សញ្ជាតិ....................មុខរបរបច្ចុប្បន្ន .....................
អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ..............ផ្លូវ..............ភូមិ.........................ឃុំ/សង្កាត់.............................ក្រុង/ស្រុក/ខណ្ឌ...................................រាជធានី/ខេត្ត.........................
កាន់អត្តសញ្ញាណប័ណ្ណលេខ..............................ចេញដោយ.............................................................................................................................................
ធ្វើអាជីវកម្មប្រមូលទិញសត្វ /ផលិតផលមានដើមកំណើតពីសត្វ..........................ចំនួន......................ក្បាល/ គ.ក្រ ឆ្នាំ ដើម្បី...................................................នៅ...............................
ស្ថិតនៅ: ភូមិ..............................ឃុំ/សង្កាត់.......................................ក្រុង/ស្រុក/ខណ្ឌ.......................................រាជធានី/ខេត្ត.......................................។
លិខិតអនុញ្ញាតនេះ មានសុពលភាពចាប់ពីថ្ងៃទី...........ខែ..................ឆ្នាំ ២០០.......រហូតដល់ ថ្ងៃទី...........ខែ...................ឆ្នាំ ២០០.........។
សាមីជនដែលទទួលបានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មប្រមូលទិញសត្វ និងផលិតផលមានដើមកំណើតពីសត្វត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារដូចមានចែងក្នុងកិច្ចសន្យាធ្វើអាជីវកម្ម និង លិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធជាធរមាន ដើម្បីដំណើរការអាជីវកម្មឱ្យបានល្អប្រសើរ។

រាជធានីភ្នំពេញ ថ្ងៃទី ............. ខែ ........... ឆ្នាំ ២០០...........

**ប្រធាននាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត
៤ x ៦

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល
លេខ :........................ផប.លអ

## លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

- យោងអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- យោងប្រកាសលេខ........................ប្រក.កសក ចុះថ្ងៃទី................ខែ..............ឆ្នាំ២០០......ស្តីពីនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- យោងលិខិត..........................កសក.ចុះថ្ងៃទី.................ខែ.......................ឆ្នាំ ២០០.........របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

បានអនុញ្ញាតឱ្យលោក/លោកស្រី..........................................ភេទ..........អាយុ..........ឆ្នាំ ជនជាតិ..............សញ្ជាតិ..................មុខរបរបច្ចុប្បន្ន ..................
អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ..............ផ្លូវ..............ភូមិ....................ឃុំ/សង្កាត់..............................ក្រុង/ស្រុក/ខណ្ឌ..............................រាជធានី/ខេត្ត........................
កាន់អត្តសញ្ញាណប័ណ្ណលេខ..............................ចេញដោយ..............................................................................................................
ធ្វើអាជីវកម្មប្រមូលទិញសត្វ /ផលិតផលមានដើមកំណើតពីសត្វ............................ចំនួន....................ក្បាល/ គ.ក្រ ឆ្នាំ ដើម្បី.....................................នៅ..............................
ស្ថិតនៅៈ ភូមិ...............................ឃុំ/សង្កាត់.........................................ក្រុង/ស្រុក/ខណ្ឌ..................................................រាជធានី/ខេត្ត.......................................។
លិខិតអនុញ្ញាតនេះ មានសុពលភាពចាប់ពីថ្ងៃទី..........ខែ..................ឆ្នាំ ២០០.......រហូតដល់ ថ្ងៃទី............ខែ....................ឆ្នាំ ២០០.........។
សាមីជនដែលទទួលបានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មប្រមូលទិញសត្វ និងផលិតផលមានដើមកំណើតពីសត្វត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារដូចមានចែងក្នុងកិច្ចសន្យាធ្វើអាជីវកម្ម និង លិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធជាធរមាន ដើម្បីដំណើរការអាជីវកម្មឱ្យបានល្អប្រសើរ។

រាជធានីភ្នំពេញ ថ្ងៃទី ............. ខែ ........... ឆ្នាំ ២០០...........

**ប្រធាននាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត ៤x៦

មន្ទីរកសិកម្មរាជធានី/ខេត្ត..............................

ការិយាល័យ ផលិតកម្ម និង បសុពេទ្យាបាល

លេខ :.........................កជប.លអ

## លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

- យោងអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្ដីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- យោងប្រកាសលេខ.........................ប្រក.កសក ចុះថ្ងៃទី...............ខែ..............ឆ្នាំ២០០......ស្ដីពីនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- យោងលិខិត........................... កសក.ចុះថ្ងៃទី...............ខែ....................ឆ្នាំ ២០០............របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

បានអនុញ្ញាតឱ្យលោក/លោកស្រី..................................................ភេទ..............អាយុ..........ឆ្នាំ ជនជាតិ..................សញ្ជាតិ..................មុខរបរបច្ចុប្បន្ន .........................

អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ...............ផ្លូវ...............ភូមិ...................ឃុំ/សង្កាត់...........................ក្រុង/ស្រុក/ខណ្ឌ.......................................រាជធានី/ ខេត្ត..........................

កាន់អត្តសញ្ញាណប័ណ្ណលេខ.................................ចេញដោយ............................................................................................................................................

ធ្វើអាជីវកម្មប្រមូលទិញសត្វ /ផលិតផលមានដើមកំណើតពីសត្វ..................ចំនួន.......................ក្បាល/ គ.ក្រ ឆ្នាំ ..........ដើម្បី...............................នៅ..........................................

ស្ថិតនៅ: ភូមិ.......................................ឃុំ/សង្កាត់..............................................ក្រុង/ស្រុក/ខណ្ឌ.................................................រាជធានី/ ខេត្ត........................................ ។

លិខិតអនុញ្ញាតនេះ មានសុពលភាពចាប់ពីថ្ងៃទី...........ខែ...................ឆ្នាំ ២០០.......រហូតដល់ ថ្ងៃទី............ខែ......................ឆ្នាំ ២០០.......... ។

សាមីជនដែលទទួលបានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារដូចមានចែងក្នុងកិច្ចសន្យាធ្វើអាជីវកម្ម និង លិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធជាធរមាន ដើម្បីដំណើរការអាជីវកម្មឱ្យបានល្អប្រសើរ ។

.........................ថ្ងៃទី ............. ខែ ........... ឆ្នាំ ២០០............

**ប្រធានការិយាល័យផលិតកម្ម និងបសុពេទ្យាបាល**

បានឃើញ និង ឯកភាព

...........ថ្ងៃទី .............. ខែ ........... ឆ្នាំ ២០០..........

**ប្រធានមន្ទីរកសិកម្ម**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
Ministry of Agriculture, Forestry and Fisheries
នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល
Department of Animal Health and Production

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

លេខ :..................ផ.ប.រិអ

# ទិញ្ញាបនបត្រអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
# Sanitary Certificate of Animal and Animal Products

- ប្រភេទសត្វ :..........................................Species : ..........................................................................
- ចំនួនសត្វសរុប:..........................................ក្បាល ឈ្មោល :................ក្បាល ញី :........................ក្បាល
- Total number: ...................................... head(s), Male.................head(s), Female...........head(s)
- អត្តសញ្ញាណ:..........................................Identification :...........................................................
- ប្រភេទផលិតផល :.................................Type of products :...................................................
- ចំនួនផលិតផល ឬ កញ្ចប់ :..........................Number of products or packages :..............................
- ទម្ងន់សរុប :..........................................Net weight..........................................................................
- របៀបវេចខ្ចប់ :..........................................Type of package :...............................................................
- ដឹកជញ្ជូនចេញពី: ភូមិ /ទីតាំង...................................ឃុំ/សង្កាត់...........................................................
- Departure from: Village/ Location :.....................Commune/Sangkat :........................................
  ក្រុង/ស្រុក/ខណ្ឌ :.............................................រាជធានី/ខេត្ត :..............................................................
  City/District/Khan :.............................................Municipality/Province :...........................................
- ឆ្ពោះទៅកាន់ ភូមិ ..............................................ឃុំ/សង្កាត់...........................................................
- Destination :Village.............................................Commune/Sangkat.............................................
  ក្រុង/ស្រុក/ខណ្ឌ :.........................រាជធានី /ខេត្ត :..............................ប្រទេស :..........................
  City/District/Khan : ........................Municipality/Province :..............Country :.............................
- តាមច្រក:.......................................................Exit point :............................................................
- អ្នកនាំចេញ : ឈ្មោះ...........................................មុខរបរ...........................................................
- Name of exporter :.............................................Occupation :.......................................................
- អាសយដ្ឋាន ...........................................................................................................................
- Address :.............................................................................................................................
- អ្នកទទួល : ឈ្មោះ ...............................................មុខរបរ.........................................................
- Name of consignee :............................................Occupation :.......................................................
- អាសយដ្ឋាន : .........................................................................................................................
- Address :..............................................................................................................................
- មធ្យោបាយដឹកជញ្ជូន:............................................Means of transport :...........................................
- ថ្ងៃ ខែ ឆ្នាំ ដឹកជញ្ជូនចេញ:......................................Date of departure :...............................................
- យោបល់បសុពេទ្យ:....................................................................................................................
..............................................................................................................................................
- Veterinary attestation :..........................................................................................................
..............................................................................................................................................
- សុពលភាពៈពីថ្ងៃទី................ខែ.............ឆ្នាំ.................ដល់ ថ្ងៃទី.............ខែ.............ឆ្នាំ...................
- Validity: Date :.....................................................until to: Dat :..................................................

ធ្វើនៅ.........................ថ្ងៃទី.........ខែ...........ឆ្នាំ ២០០....
Issue at......................on...........................................

បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ,ថ្ងៃទី.........ខែ...........ឆ្នាំ ២០០....

ប្រធាននាយកដ្ឋាន ផលិតកម្ម និងបសុព្យាបាល
Director , DAHP